25,16		ថ្មក្រានីត ពរហ្វៀរ បាសាល់ ថ្មសំណៀង និងថ្មផ្សេងទៀត សំរាប់សំណង់ទោះបីជា ដុំតូច ធំដោយអារ ឬវិធីផ្សេង ជាផ្ទាំង ឬបន្ទះបួនជ្រុងស្មើ ឬទ្រវែង ។	Granite, porphyry, basalt, sandstone and other monumental or building stone, whether or not roughly trimmed or merely cut, by sawing or otherwise, into blocks or slabs of a rectangular (including square) shape.									
	2516.11.00	- - មិនទាន់ច្នៃ ឬធ្វើអោយគ្រាត	- - Crude or roughly trimmed	kg	7	0	10	0	7	0	10	10
	2516.12.10	- - - ដុំ	- - - Blocks	kg	7	0	10	0	7	0	10	10
	2516.12.20	- - - បន្ទះ	- - - Slabs	kg	7	0	10	0	7	0	10	10
	2516.20.00	- ថ្មភក់	- Sandstone	kg	7	0	10	0	7	0	10	10
	2516.90.00	- ថ្មសំរាប់សាងសង់ផ្សេងទៀត	- Other monumental or building stone	kg	7	0	10	0	7	0	10	10
25,17		គ្រួសថ្មអាចម៍ផ្កាយតូច ធំ ថ្មបំបែករួចហើយ ដែលជាទូទៅ សំរាប់ចាក់បេតុង និងក្រាលថ្នល់ ក្រាលផ្លូវដែក ឬក្រាលផ្សេងទៀត គ្រួស និងស៊ីឡិច ទោះបីជាកែច្នៃ ដោយកំដៅ ថ្មក្រាល ម៉ាកាដាម អាចម៍លោហធាតុ រលាយ ឬសំណល់ ឧស្សាហកម្មប្រហាក់ប្រហែលទោះជា វានៅក្នុងរូបធាតុនៃភាគខាងលើក៏ដោយ ថ្មលាយកៅស៊ូ ក្រាលថ្នល់ជាគ្រាប់ល្អិត ឬជាអំបែង និងជាម្សៅថ្មក្នុងចំណងលេខ ២៥.១៥ ឬ ២៥.១៦ ដែល កែច្នៃដោយកំដៅ។	Pebbles, gravel, broken or crushed stone, of a kind commonly used for concrete aggregates, for road metalling or for railway or other ballast, shingle and flint, whether or not heat-treated; macadam of slag, dross or similar industrial waste, whether or not incorporating the materials cited in the first part of the heading; tarred macadam; granules, chippings and powder, of stones of heading No. 25.15 or 25.16, whether or not heat-treated :									

	2517.20.00	- ថ្មក្រាលម៉ាកាដាម អាចម៍លោហៈធាតុរលាយ ឬ សំណល់ឧស្សាហកម្ម ប្រហាក់ប្រហែល ទោះជានៅក្នុងរូបធាតុនៃទិតាំងរងលេខ ២៥១៧.១០	- Macadam of slag, dross or similar industrial waste, whether or not incorporating the materials cited in subheading No. 2517.10	kg	7	0	10	[illegible]	7	0	10	[illegible]
	2517.30.00	- ថ្មលាយកៅស៊ូក្រាលថ្នល់	- Tarred Macadam	kg	7	0	10	[illegible]	7	0	10	[illegible]
	2517.41.00	- - នៃថ្មម៉ាប	- - Of marble	kg	7	0	10	[illegible]	7	0	10	[illegible]
	2517.49.00	- - ផ្សេងទៀត	- - Other	kg	7	0	10	[illegible]	7	0	10	10
25,18		ថ្មដូឡូមីត ទោះបីដុតសុស ឬដុតរលាយ ថ្មដូឡូមីតតូចធំបានមកពីការអារ ឬវិធី ផ្សេងទៀតជាដុំៗ ឬជាបន្ទះរាងបួនជ្រុងស្មើ ឬទ្រវែង ថ្មដូឡូមីត ដោយជាន់ឱ្យស្អិតសំរាប់សាងសង់ ។	Dolomite, whether or not calcined or sintered;including dolomite roughly trimmed or merely cut, by sawing or otherwise, into blocks or slabs of a rectangular (including square) shape; dolomite ramming mix.									
	2518.10.00	- ថ្មដូឡូមីតមិនដុតឱ្យសុស	- Dolomite not calcined or sintered	kg	15	0	10	[illegible]	15	0	10	10
	2518.20.00	- ថ្មដូឡូមីតដែលដុតសុស	- Calcined or sintered dolomite	kg	15	0	10	[illegible]	15	0	10	10
	2518.30.00	- ថ្មដូឡូមីត ដែលជាន់ឱ្យស្អិតសំរាប់សាងសង់ (ថ្មដូឡូមីតលាយកៅស៊ូ ក្រាលថ្នល់)	- dolomite ramming mix	kg	15	0	10	0	15	0	10	10
25,19		ម៉ាញ៉េស្យូមកាបូណាតធម្មជាតិ(ម៉ាញ៉េស៊ីត) ម៉ាញ៉េស្យូមរលាយដោយអគ្គីសនី ឬដុតរលាយ ទោះបីមានបរិមាណតិចតួចនៃអុកស៊ីតដទៃទៀត បន្ថែមមុនពេលដុតរលាយ ក៏ដោយ ម៉ាញ៉េស្យូមអុកស៊ីតដទៃទៀត ទោះបីសុទ្ធឬមិនសុទ្ធក៏ដោយ ។	Natural magnesium carbonate (magnesite); fused magnesia; dead-burned (sintered) magnesia, whether or not containing small quantities of other oxides added before sintering; other magnesium oxide, whether or not pure.									
	2519.10.00	- ម៉ាញ៉េស្យូមកាបូណាតធម្មជាតិ	- Natural magnesium carbonate (magnesite)	kg	15	0	10	0	15	0	10	[illegible]

	2519.90.00	- ផ្សេងទៀត	- Other	kg	15	0	10	0	15	0	10	10
25,20		ថ្មហ្សីប(ម្នាងសិលា)អានីឌ្រីដ ថ្មផ្សាតនោះបិលាយពណ៌ បន្ថែមសារជាតិ ពន្លឿនឬពន្យឺតភាពរឹង ។	Gypsum; anhydrite; plasters (consisting of calcined gypsum or calcium sulphate) whether or not coloured, with or without small quantities of accelerators or retarders.									
	2520.10.00	- ថ្មហ្សីប អានីឌ្រីដ	- Gypsum , anhydrite	kg	7	0	10	0	7	0	10	10
	2520.20.10	- - សំរាប់ប្រើក្នុងវិជ្ជាធ្មេញ	- - For use in dentistry	kg	7	0	10	0	7	0	10	10
	2520.20.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	7	0	10	10
25,21	2521.00.00	ថ្មកំបោរកាលទីន ថ្មសំរាប់ធ្វើកំបោរ ឬស៊ីម៉ង់ត៍	Limestone flux; limestone and other calcareous stone, of a kind used for the manufacture of lime or cement.	kg	7	0	10	0	7	0	10	10
25,22		ថ្មកំបោររស់ ថ្មកំបោរងាប់ និងថ្មកំបោរប្រើក្នុងទឹក លើកលែងតែ កាល់ស្យូម អុកស៊ីដ ឬអ៊ីដ្រុកស៊ីតចេញនៅក្នុងទីតាំងលេខ ២៨.២៥ ។	Quicklime, slaked lime and hydraulic lime, other than calcium oxide and hydroxide of heading No. 28.25.									
	2522.10.00	- ថ្មកំបោររស់	- Quicklime	kg	7	0	10	0	7	0	10	10
	2522.20.00	- ថ្មកំបោរងាប់	- Slaked lime	kg	7	0	10	0	7	0	10	10
	2522.30.00	- ថ្មកំបោរប្រើក្នុងទឹក	- Hydraulic lime	kg	7	0	10	0	7	0	10	10
25,23		ស៊ីម៉ង់ត៍ទឹក " ប្រើក្នុងទឹក " រាប់បញ្ចូលទាំង ស៊ីម៉ង់ត៍មិនទាន់កិន នោះបិលាយ ពណ៌ក៏ដោយ ។	Portland cement, aluminous cement, slag cement, supersulphate cement and similar hydraulic cements, whether or not coloured or in the form of clinkers.									
	2523.10.10	- - ស៊ីម៉ង់ត៍ស	- - For white cement	kg	15	0	10	0	15	0	10	10
	2523.10.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	15	0	10	10

	2523.21.00	- - ស៊ីម៉ងត៍សទោះបីជាមានពណ៌តាមបែបសិប្បនិម្មិតក៏ដោយ	- - White Cement, whether or not artificially coloured	kg	15	0	10	0	15	0	10	10
	2523.29.10	- - - ស៊ីម៉ងត៍ពណ៌	- - - Colour cement	kg	15	0	10	0	15	0	10	10
	2523.29.90	- - - ផ្សេងទៀត	- - - Other	kg	15	0	10	0	15	0	10	10
	2523.30.00	- ស៊ីម៉ងត៍មានជាតិអាលុយមីញ៉ូម	- Aluminous Cement	kg	15	0	10	0	15	0	10	10
	2523.90.00	- ស៊ីម៉ងត៍ ប្រើក្នុងទឹកដទៃទៀត	- Other Hydraulic cements	kg	15	0	10	0	15	0	10	10
25,24		អាមីញ៉ង់ ។	Asbestos.									
	2524.10.00	- ក្រូស៊ីដូលិត	- Crocidolite	kg	7	0	10	0	7	0	10	10
	2524.90.00	- ផ្សេងទៀត	- Other	kg	7	0	10	0	7	0	10	10
25,25		ថ្មមីកា រាប់បញ្ចូលទាំងមីកាបន្ទះមិនស្មើជ្រុង (splitting) សំណល់មីកា	Mica, including splittings; mica waste.									
	2525.10.00	- ថ្មមីកាមិនទាន់ច្នៃ និងថ្មមីកាជាសន្លឹក ឬជាបន្ទះមិនស្មើជ្រុង	- Crude mica and mica [illegible] splittings	kg	7	0	10	0	7	0	10	10
	2525.20.00	- ម្សៅថ្មមីកា	- Mica powder	kg	7	0	10	0	7	0	10	10
	2525.30.00	- កាកសំណល់មីកា	- Mica waste	kg	7	0	10	0	7	0	10	10
25,26		ថ្មស្លេអាទីតធម្មជាតិ ទោះបីជាធ្វើឱ្យទៅក្លូច ឬបំបែកទៀត បានមកពី ការអារ ឬវិធីផ្សេង ជាដុំៗ ឬបន្ទះមូលជ្រុងស្មើ ឬទ្រវែងបួនជ្រុង ថ្មតាល់ ។	Natural steatite, whether [illegible] trimmed or merely cut, by sawing or otherwise, into blocks or slabs of a rectangular (including square) shape; talc.									
	2526.10.00	- មិនបំបែក មិនកិនជាម្សៅ	- not crushed, not powdered	kg	15	0	10	0	15	0	10	10
	2526.20.10	- - ម្សៅតាល់	- - Talc powder	kg	15	0	10	0	15	0	10	10
	2526.20.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	15	0	10	10

25,28		អំបិលបូរ៉ាតធម្មជាតិ ឬល្បាយវាបស់វា (ដុតសុស ឬមិនដុត) លើកលែងតែ បូរ៉ាត ចំរាញ់យកពីសិលាមាន ជាតិអំបិល អាស៊ីតបូរិក ធម្មជាតិ ដែលមាន ផលិតផលឌី បរិមាណស៊ីត ៨៥ % នៃ H_3BO_3 លើផលិតផលស្ងួត ។	Natural borates and concentrates thereof (whether or not calcined), but not including borates separated from natural brine; natural boric acid containing not more than 85 % of H3B03 calculated on the dry weight.									
	2528.10.00	- អំបិលសូដ្យូមបូរ៉ាតធម្មជាតិ និងល្បាយវាបស់វា (ទោះបីដុតសុស ឬដុតមិនសុសក៏ដោយ) ។	- Natural sodium borates and concentrates thereof (whether or not calcined)	kg	15	0	10	[illegible]	15	0	10	10
	2528.90.00	- ផ្សេងទៀត	- Other	kg	15	0	10	[illegible]	15	0	10	10
25,29		ហ្វែលស្ពាត ឡឺស៊ីត ណេហ្វ៊ីលីន និងថ្មណេហ្វ៊ីលីនស៊ីយេនីត ស្ពាតហ្លុយអ័រ	Felspar; leucite; nepheline and nepheline syenite;fluorspar.									
	2529.10.00	- ហ្វែលស្ពាត	- Felspar	kg	15	0	10	0	15	0	10	10
	2529.21.00	- - មានកាល់ស្យូមហ្លុយអ័រទំងន់ត្រឹម ៩៧ % ឬតិចជាងនេះ	- - Containing by weight 97 % or less of calcium fluoride	kg	15	0	10	0	15	0	10	10
	2529.22.00	- - មានកាល់ស្យូមហ្លុយអ័រទំងន់លើសពី ៩៧ %	- - Containing by weight more than 97 % of calcium fluoride	kg	15	0	10	0	15	0	10	10
	2529.30.00	- ឡឺស៊ីត ណេហ្វ៊ីលីន និងថ្មណេហ្វ៊ីលីនស៊ីយេនីត	- Leucite, nepheline and nepheline syenite	kg	15	0	10	0	15	0	10	10
25,30		វត្ថុធាតុដែលគ្មានឈ្មោះ និងមិនរាប់បញ្ចូលនៅកន្លែងផ្សេងទៀត	Mineral substances not elsewhere specified or included.									
	2530.10.00	- វែមីគុយលីត ពែរលីត និងក្លរីត	- Vermiculite, perlite and chlorites, unexpanded	kg	15	0	10	0	15	0	10	10
	2530.20.10	- - គីស៊ើរីត	- - Kieserite	kg	15	0	10	0	15	0	10	10
	2530.20.20	- - អិបសូមីត	- - Epsomite	kg	15	0	10	0	15	0	10	10
	2530.90.00	- - ផ្សេងទៀត	- - Other	kg	15	0	10	0	15	0	10	10

26,01		រ៉ែដែក និងល្បាយខាប់របស់វារួមទាំងដែកពៀរីតដុត	Iron ores and concentrates, including roasted iron pyrites									
	2601.11.00	- - មិនប្រមូលផ្តុំគ្នា	- - Non-agglomerated	kg	0	0	10	0	0	0	10	10
	2601.12.00	- - ប្រមូលផ្តុំគ្នា	- - Agglomerated	kg	0	0	10	0	0	0	10	10
	2601.20.00	- ដែកពៀរីតដុត	- Roasted iron pyrites	kg	0	0	10	0	0	0	10	10
26,02	2602.00.00	រ៉ែម៉ង់កាណែស និងល្បាយខាប់របស់វារាប់បញ្ចូលទាំងរ៉ែដែកដែលមានជាតិម៉ង់កាណែសក្នុង ២០% ឬលើសពីនេះជាទម្ងន់លើផលិតផលស្ងួត ។	Manganese ores and concentrates, including ferruginous manganese ores and concentrates with a manganese content of 20% or more, calculated on the dry weight.	kg	0	0	10	0	0	0	10	10
26,03	2603.00.00	រ៉ែទង់ដែង និងល្បាយខាប់របស់វា	Copper ores and concentrates.	kg	0	0	10	0	0	0	10	10
26,04	2604.00.00	រ៉ែនីកែល និងល្បាយខាប់របស់វា	Nickel ores and concentrates.	kg	0	0	10	0	0	0	10	10
26,05	2605.00.00	រ៉ែកូបាល់ និងល្បាយខាប់របស់វា	Cobalt ores and concentrates.	kg	0	0	10	0	0	0	10	10
26,06	2606.00.00	រ៉ែអាលុយមីញ៉ូម និងល្បាយខាប់របស់វា	Aluminium ores and concentrates.	kg	0	0	10	0	0	0	10	10
26,07	2607.00.00	រ៉ែសំណ និងល្បាយខាប់របស់វា	Lead ores and concentrates.	kg	0	0	10	0	0	0	10	10
26,08	2608.00.00	រ៉ែស័ង្កសី និងល្បាយខាប់របស់វា	Zinc ores and concentrates.	kg	0	0	10	0	0	0	10	10
26,09	2609.00.00	រ៉ែសំណប៉ាហាំង និងល្បាយខាប់របស់វា	Tin ores and concentrates.	kg	0	0	10	0	0	0	10	10
26,10	2610.00.00	រ៉ែក្រូម និងល្បាយខាប់របស់វា	Chromium ores and concentrates.	kg	0	0	10	0	0	0	10	10
26,11	2611.00.00	រ៉ែតង់ស្តែន និងល្បាយខាប់របស់វា	Tungsten ores and concentrates.	kg	0	0	10	0	0	0	10	10
26,12		រ៉ែអ៊ុយរ៉ានីញ៉ូម ឬតូរីញ៉ូម និងល្បាយខាប់របស់វា	Uranium or thorium ores and concentrates.									

	2612.10.00	- រ៉ែអ៊ុយរ៉ានីញ៉ូម និងល្បាយកាច់របស់វា	- Uranium ores and concentrates	kg	0	0	10		0	0	10	
	2612.20.00	- រ៉ែថូរីញ៉ូម និងល្បាយកាច់របស់វា	- Thorium ores and concentrates	kg	0	0	10		0	0	10	
26,13		រ៉ែម៉ូលីបដែន និង ល្បាយកាច់របស់វា	**Molybdenum ores and concentrates.**									
	2613.10.00	- ដុត	- Roasted	kg	0	0	10		0	0	10	
	2613.90.00	- ផ្សេងទៀត	- Other	kg	0	0	10		0	0	10	
26,14		រ៉ែទីតាន និងល្បាយកាច់របស់វា	**Titanium ores and concentrates.**									
	2614.00.10	- រ៉ែអ៊ីលមេនិត និងល្បាយរបស់វា	- Ilmenite ores and concentrates	kg	0	0	10		0	0	10	
	2614.00.90	- ផ្សេងទៀត	- Other	kg	0	0	10		0	0	10	
26,15		រ៉ែនីយ៉ូប្យូម រ៉ែតង់តាល្យូម រ៉ែវ៉ាណាដ្យូម ឬហ្ស៊ីកូនីញ៉ូម និងល្បាយកាច់របស់វា	**Niobium, tantalum, vanadium or zirconium ores and concentrates.**									
	2615.10.00	- រ៉ែហ្ស៊ីកូនីញ៉ូម និងល្បាយកាច់របស់វា	- Zirconium ores and concentrates	kg	0	0	10		0	0	10	
	2615.90.00	- ផ្សេងទៀត	- Other	kg	0	0	10		0	0	10	
26,16		រ៉ែនៃលោហធាតុមានតម្លៃ និងល្បាយកាច់របស់វា	**Precious metal ores and concentrates.**									
	2616.10.00	- រ៉ែប្រាក់ និងល្បាយកាច់របស់វា	- Silver ores and concentrates	kg	0	0	10		0	0	10	
	2616.90.00	- ផ្សេងទៀត	- Other	kg	0	0	10		0	0	10	
26,17		រ៉ែផ្សេងទៀត និងល្បាយកាច់របស់វា	**Other ores and concentrates.**									
	2617.10.00	- រ៉ែអង់ទីម៉ូនី និងល្បាយកាច់របស់វា	- Antimony ores and concentrates	kg	0	0	10		0	0	10	
	2617.90.00	- ផ្សេងទៀត	- Other	kg	0	0	10		0	0	10	

26.18	2618.00.00	អាចម៍លោហៈជាគ្រាប់ល្អិតៗ (ខ្សាច់អាចម៍លោហៈ) សំណល់នៃការផលិតដែកឬដែកថែប ។	Granulated slag (slag sand) from the manufacture of iron or steel.	kg	0	0	10	[redacted]	0	0	10	[redacted]
26.19	2619.00.00	សំណល់ អាចម៍លោហៈជាគ្រាប់ល្អិតៗ (ក្រៅពីអាចម៍លោហៈជាគ្រាប់ល្អិតៗ ខ្សាច់អាចម៍លោហៈ) អាចម៍ដែក សំណល់ដទៃទៀតពីការផលិតដែក និង ដែកថែប ។	Slag, dross (other than granulated slag), scalings and other waste from the manufacture of iron or steel.	kg	0	0	10	[redacted]	0	0	10	[redacted]
26.20		ផេះ និងសំណល់ (ក្រៅពីផលិតកម្មដែក ឬដែកថែប) ដែលមានលោហៈ ឬ សមាសធាតុលោហៈ ។	Ash and residues (other than from the manufacture of iron or steel), containing arsenic, metal or their compounds.					[redacted]				[redacted]
	2620.11.00	- - កាកស័ង្កសីរឹង	- - Hard zinc spelter	kg	0	0	10	[redacted]	0	0	10	[redacted]
	2620.19.00	- - ផ្សេងៗទៀត	- - Other	kg	0	0	10	[redacted]	0	0	10	[redacted]
	2620.21.00	- - កាកសំណល់ប្រេងសាំងមានជាតិសំណ និងកាកសមាសធាតុប្រឆាំងការផ្ទុះដែលមានជាតិសំណ	- - Lead gasoline sludges and leaded anti-knock compound sludges	kg	0	0	10	[redacted]	0	0	10	[redacted]
	2620.29.00	- - ផ្សេងៗទៀត	- - Other	kg	0	0	10	[redacted]	0	0	10	[redacted]
	2620.30.00	- ដែលមានភាគច្រើនជាទង់ដែង	- Containing mainly copper	kg	0	0	10	[redacted]	0	0	10	[redacted]
	2620.40.00	- ដែលមានភាគច្រើនជាអាលុយមីញ៉ូម	- Containing mainly aluminium	kg	0	0	10	[redacted]	0	0	10	[redacted]
	2620.60.00	- ដែលមាន អាសេនិច បារត តាលីញ៉ូម ឬល្បាយរបស់វា ប្រភេទដែលប្រើប្រាស់សម្រាប់ការចម្រាញ់អាសេនិច ឬលោហធាតុទាំងនោះ ឬសម្រាប់ផលិតសមាសធាតុគីមីរបស់វា	- Containing arsenic, mercury, thallium or their mixtures, of a kind used or the extraction of arsenic or those metal or for the manufacture of their chemical compounds	kg	0	0	10	[redacted]	0	0	10	[redacted]
	2620.91.00	- - ដែលមាន អង់ទីម៉ូនី បេរីល្យូម កាដម្យូម ក្រូមីញ៉ូម ឬល្បាយរបស់វា	- - Containing antimony, beryllium, cadmium, chromium or their mixtures	kg	0	0	10	[redacted]	0	0	10	[redacted]

	2620.99.00	- - ផ្សេងទៀត	- - Other	kg	0	0	10		0	0	10	
26,21		អាចម៌លោហៈផ្សេងទៀត និងផេះ ដោយរាប់បញ្ចូលទាំងផេះ ស្លែសារាយសមុទ្រ និងកាកសំណល់បានពីការដុតកាកសំណល់តាមទីក្រុង	**Other slag and ash, including seaweed ash (kelp);ash and residues from the incineration of municipal waste.**									
	2621.10.00	- ផេះ និង សំណល់ បានពីការដុតកាកសំណល់តាមទីក្រុង	- Ash and residues from the incineration of municipal waste	kg	0	0	10		0	0	10	
	2621.90.00	- ផ្សេងទៀត	- Other	kg	0	0	10		0	0	10	
27,01		ធ្យូងថ្ម ដុំធ្យូងថ្ម ប្រើជាគ្រឿងដុតរាងពងក្រពើ និងគ្រឿងដុតរឹងប្រហាក់ប្រហែល ដែលយកចេញពីធ្យូងថ្ម ។	**Coal; briquettes, ovoids and similar solid fuels manufactured from coal.**									
	2701.11.00	- - ធ្យូងអង់ត្រាស៊ីត	- - Anthracite	kg	0	0	10		0	0	10	
	2701.12.10	- - - ធ្យូងកូក	- - - Coking coal	kg	0	0	10		0	0	10	
	2701.12.90	- - - ផ្សេងទៀត	- - - Other	kg	0	0	10		0	0	10	
	2701.19.00	- - ធ្យូងថ្មផ្សេងទៀត	- - Other coal	kg	0	0	10		0	0	10	
	2701.20.00	- ដុំធ្យូងថ្មប្រើជាគ្រឿងដុតរាងពងក្រពើ ឬគ្រឿងដុតប្រហាក់ប្រហែលដែលយក ចេញពីធ្យូងថ្ម	- Briquettes, ovoids and similar solid fuels manufactured from coal	kg	0	0	10		0	0	10	
27,02		ធ្យូងលីញីតទោះបីប្រមូលផ្តុំក៏ដោយ លើកលែងតែថ្មជេត	**Lignite, whether or not agglomerated, excluding jet.**									
	2702.10.00	- ធ្យូងថ្មលីញីតទោះបីជាកិនកំទេចឬមិនកំទេចក៏ដោយ តែមិនប្រមូលផ្តុំទេ	- Lignite, whether or [illegible] but not agglomerated	kg	0	0	10		0	0	10	
	2702.20.00	- ធ្យូងថ្មលីញីតដែលប្រមូលផ្តុំ	- Agglomerated lignite [illegible]	kg	0	0	10		0	0	10	

27.03		[illegible]	Peat (including peat litter), whether or not agglomerated.									
	2703.00.10	- [illegible]	- Peat, whether or not compressed into bales, but not agglomerated	kg	[illegible]	0	10	[illegible]	0	0	10	[illegible]
	2703.00.20	- [illegible]	- Agglomerated peat	kg	4	0	10	[illegible]	0	0	10	[illegible]
27.04		[illegible]	Coke and semi-coke of coal, of lignite or of peat, whether or not agglomerated; retort carbon.									
	2704.00.10	- [illegible]	- Coke and semi-Coke of coal	kg	[illegible]	0	10	[illegible]	[illegible]	0	10	[illegible]
	2704.00.20	- [illegible]	- Coke and semi-Coke of lignite or of peat	kg	[illegible]	0	10	[illegible]	4	0	10	[illegible]
	2704.00.30	- [illegible]	- Retort carbon	kg	4	0	10	[illegible]	[illegible]	0	10	[illegible]
27.05	2705.00.00	[illegible]	Coal gas, water gas, producer gas and similar gases, other than petroleum gases and other gaseous hydrocarbons.	kg	4	0	10	[illegible]	[illegible]	0	10	[illegible]
27.09		[illegible]	Petroleum oils and oils obtained from bituminous minerals, crude.									
	2709.00.10	- [illegible]	- Crude petroleum oil	kg	[illegible]	0	10	[illegible]	[illegible]	0	10	[illegible]
	2709.00.20	- [illegible]	- Condensate	kg	[illegible]	0	10	[illegible]	[illegible]	0	10	[illegible]
72.04		[illegible]	Ferrous waste and scrap; remelting scrap ingots of iron or [illegible]									
	7204.10.00	- [illegible]	- Waste and [illegible]	kg	[illegible]	0	10	[illegible]	[illegible]	0	10	[illegible]

[illegible]

	7204.21.00	- - ពីដែកថែបមិនច្រេះ	- - Of stainless steel	kg	7	0	10		7	0	10	
	7204.29.00	- - ផ្សេងៗទៀត	- - Other	kg	7	0	10		7	0	10	
	7204.30.00	- កាកសំណល់ និងកំទេចនៃដែកស្រោប-ដែកស៊ីន សំណប៉ាហាំង	- Waste and scrap of tinned iron or steel	kg	7	0	10		7	0	10	
	7204.41.00	- - អាចម៍ដែកឈូស ចំណិត កំទេចក្រឡឹង កំទេចពីការឈូសក្រាស់ កំទេចពីការកាត់ច្រឹប កំទេចពីការពត់គូ កំទេចពីការបោះត្រា ។	- - Turnings, shavings, chips, milling waste, sawdust, filings, trimmings and stampings, whether or not in bundles	kg	7	0	10		7	0	10	
	7204.49.00	- - ផ្សេងៗទៀត	- - Other	kg	7	0	10		7	0	10	
	7204.50.00	- សំណល់ពាក់ជាដុំ	- Remelting scrap ingots	kg	7	0	10		7	0	10	
74.04	7404.00.00	កំទេចនិងកាកសំណល់ស្ពាន់	Copper waste and scrap.	kg	7	0	10		7	0	10	
76.02	7602.00.00	កាកសំណល់ និងកំទេចអាលុយមីញ៉ូម	Aluminium waste and scrap.	kg	7	0	10		7	0	10	
78.02	7802.00.00	កាកសំណល់ និងកំទេចសំណ	Lead waste and scrap.	kg	7	0	10		7	0	10	
79.02	7902.00.00	កាកសំណល់ និងកំទេចស័ង្កសី ។	Zinc waste and scrap.	kg	7	0	10		7	0	10	
80.02	8002.00.00	កាកសំណល់ និងកំទេចសំណប៉ាហាំង	Tin waste and scrap.	kg	7	0	10		7	0	10	

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រែក្លាយសាលាជំនាញបច្ចេកទេសចម្រុះទៅជា វិទ្យាស្ថានបច្ចេកទេសយោធា តេជោ ហ៊ុន សែន

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ខែវិច្ឆិកាឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស

-បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ៣១ អនក្រ.បក ចុះថ្ងៃ ទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ៨៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានប្រែក្លាយសាលាជំនាញឯកទេសចម្រុះទៅជា **វិទ្យាស្ថានបច្ចេកទេសយោធា តេជោ ហ៊ុន សែន** ដែលសរសេរកាត់ថា **វ.ប.យ.ហ.ស.** ជាភាសាអង់គ្លេស **Techo Hun Sen Military Technical Institute (H.S.M.T.I)** ដើម្បីបណ្តុះបណ្តាលធនធានមនុស្សដល់យោធិន នៃកងយោធពលខេមរភូមិន្ទ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២

ភារកិច្ច និងការគ្រប់គ្រង

មាត្រា២.-

វ.ប.យ.ហ.ស. មានភារកិច្ចបណ្តុះបណ្តាល និងវិក្រឹត្យការលើមុខជំនាញបច្ចេកទេស ស្រាវជ្រាវបច្ចេកវិទ្យាយោធា និងចំណេះដឹងទូទៅដល់យោធិននៃកងយោធពលខេមរភូមិន្ទ និងបណ្តុះបណ្តាលមុខជំនាញបច្ចេក

ទេសយោធាកម្រិតបច្ចេកទេសមធ្យម បរិញ្ញាបត្រ វិស្វករ និងបរិញ្ញាបត្រជាន់ខ្ពស់។

មាត្រា៣.-

វ.ប.យ.ហ.ស. ធ្វើការបណ្តុះបណ្តាលលើមុខជំនាញដូចខាងក្រោម ៖

- បច្ចេកទេសយន្តសាស្ត្រ
- បច្ចេកទេសសញ្ញាវុធ
- ឯកទេសវិស្វកម្ម ភូមិសាស្ត្រ អគ្គិសនី អេឡិចត្រូនិក និងវិទ្យុទូរគមនាគមន៍
- គីមីសាស្ត្រ
- ស្រាវជ្រាវបច្ចេកវិទ្យាយោធា

ទៅថ្ងៃអនាគតយោងតាមតម្រូវការចាំបាច់ក្នុងវិស័យការពារជាតិ **វ.ប.យ.ហ.ស.** អាចពង្រីកកម្រិតបណ្តុះបណ្តាលរបស់ខ្លួនបន្ថែមទៀតបាន។

មាត្រា៤.-

វ.ប.យ.ហ.ស. ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិ។ **វ.ប.យ.ហ.ស.** មានទីតាំងនៅឃុំសំរោងទង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

មាត្រា៥.-

វ.ប.យ.ហ.ស. ដឹកនាំដោយនាយក ០១ (មួយ) រូប អមដោយនាយករងចំនួន ០៣ (បីរូប) ជាជំនួយការ។

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ **វ.ប.យ.ហ.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

ជំពូកទី៣

កម្មវិធីសិក្សា លក្ខខណ្ឌជ្រើសរើស និងការផ្តល់សញ្ញាបត្រ

មាត្រា៦.-

វ.ប.យ.ហ.ស ត្រូវរៀបចំកម្មវិធីសិក្សាបច្ចេកទេសយោធាគ្រប់កម្រិត និងគ្រប់ជំនាញ ដោយមានការឯកភាពពីក្រសួងការពារជាតិ ។

ក្រសួងការពារជាតិ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការរៀបចំកម្មវិធីសិក្សាផ្នែកចំណេះដឹងទូទៅ និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀននៅ **វ.ប.យ.ហ.ស.** តាមតម្រូវការនៃការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យការពារជាតិ។

មាត្រា៧.-

លក្ខខណ្ឌនៃការជ្រើសរើសយោធិនឱ្យចូលសិក្សានៅ **វ.ប.យ.ហ.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ដោយអនុលោមទៅតាមបទដ្ឋានស្តីពីការកំណត់លក្ខខណ្ឌនៃការចូលរៀននៅឧត្តមសិក្សា និងការសិក្សាជំនាញឯកទេស ។

មាត្រា៨.-

និស្សិតយោធិនដែលបានរៀនចប់តាមកម្មវិធីសិក្សារបស់ **វ.ប.យ.ហ.ស.** ហើយបានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា ។

សញ្ញាបត្រនេះ ត្រូវចុះហត្ថលេខាដោយនាយក **វ.ប.យ.ហ.ស.** និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

សញ្ញាបត្របញ្ចប់ការសិក្សាដែលទទួលបាននៅ **វ.ប.យ.ហ.ស.** មានតម្លៃសមមូលនឹងសញ្ញាបត្រនៃកម្រិតបណ្តុះបណ្តាលនៅគ្រឹះស្ថានឧត្តមសិក្សា ។

ជំពូកទី៤

ប្រភពធនធាន

មាត្រា៩.-

វ.ប.យ.ហ.ស. មានប្រភពធនធានមកពី ÷

- ថវិកាជាតិ ដែលស្ថិតក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងការពារជាតិ
- អំណោយពីសប្បុរសជននានា ។

វ.ប.យ.ហ.ស. មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀតពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់បម្រើសេចក្តីត្រូវការក្នុងការបំពេញការងាររបស់ខ្លួន ។

ជំពូកទី៥

អវសានបញ្ញត្តិ

មាត្រា១០.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១១.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ទៀ បាញ់

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ..១៣...អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការផ្ដល់ឥណទានថវិកា សំរាប់ការគ្រប់គ្រងឆ្នាំ ២០១០ ជូនទីស្ដីការគណៈរដ្ឋមន្ត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ , ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្ដីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០០៨ ស្ដីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២២៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ដោយអនុលោមទៅតាមមាត្រា ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៦ . ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានអនុញ្ញាតផ្តល់ឥណទានថវិកា ចំនួន ២០,០០០លានរៀល(ម្ភៃពាន់លានរៀល) ទៅលើសៀវភៅថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រីសំរាប់ការគ្រប់គ្រងឆ្នាំ២០០៩ ។

មាត្រា២: ឥណទានថវិកាដូចមានក្នុងមាត្រា ១ ខាងលើ ត្រូវបានបន្ថែមនៅជំពូក ៦៥ សម្រាប់ឥណទានពិសេសនៅក្នុងខ្ទង់ចំណាយពិសេសរបស់រាជរដ្ឋាភិបាល ដើម្បីចំណាយក្នុងកិច្ចការប្រាសាទព្រះវិហារ ។ ការបញ្ជាចំណាយនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយករដ្ឋមន្ត្រី ។

មាត្រា៣: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាបេឡាករនៃឥណទានពិសេសនេះ ។

មាត្រា៤: រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគដីសម្បទាន និងការផ្តល់ដីជូន បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស សម្រាប់បង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនកម្លាំងជាតិពិសេសប្រឆាំងភេរវកម្ម និងសាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថលើផ្ទៃប្រទេស នៅខេត្តកំពង់ឆ្នាំង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យ ប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការ ធ្វើអនុប្រយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- លិខិតលេខ ១៦៧៦ សជណ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល ។

ស ម្រេ ច

មាត្រា ១.-

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត នៃដែនដីសម្បទាន មានទំហំចំនួន ៦.៨៦២.៤៨ ហិកតា (ប្រាំមួយពាន់ប្រាំបីរយហុកសិបពីរ និងសែសិបប្រាំបីហិកតា) ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ភ្នំជំរាល ក្នុងភូមិសាស្ត្រស្រុកសាមគ្គី និងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។ ទីតាំងប្លង់ដីត្រូវបានកំណត់ក្នុងផែនទីគោលដូចមានជូនភ្ជាប់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យ ហើយមានចំណុចនិយាមកា ដូចខាងក្រោម ៖

A : X : 431157	Y : 1311994	M : X : 440655	Y : 1310502
B : X : 435976	Y : 1316014	N : X : 439781	Y : 1309771
C : X : 437954	Y : 1316008	O : X : 439946	Y : 1309436
D : X : 437802	Y : 1314120	P : X : 439798	Y : 1309354
E : X : 439019	Y : 1314242	Q : X : 439919	Y : 1308938
F : X : 439407	Y : 1314111	R : X : 432422	Y : 1309016
G : X : 440009	Y : 1314117	S : X : 437492	Y : 1310047
H : X : 440712	Y : 1312825	T : X : 436513	Y : 1308947
I : X : 442379	Y : 1312039	U : X : 436988	Y : 1308806
J : X : 442381	Y : 1310882	V : X : 436896	Y : 1306060
K : X : 442137	Y : 1310598	W : X : 431171	Y : 1306010
L : X : 441874	Y : 1311029		

មាត្រា ២.-

ត្រូវបានរំសាយផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែនដីសម្បទានរបស់ក្រុមហ៊ុន ភាពីម៉ិច Co., Ltd ។

មាត្រា ៣.-

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ៦.៨៦២.៤៨ ហិកតា (ប្រាំមួយពាន់ប្រាំបីរយហុកសិបពីរ និងសែសិបប្រាំបី ហិកតា) ដូចមានចែងក្នុងមាត្រាខាងលើ នៃអនុក្រឹត្យនេះ ដែលជាដីសម្បទានរបស់ក្រុមហ៊ុន ភាពីម៉ិច Co., Ltd មកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។

មាត្រា ៤.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សម្រាប់ផ្តល់ជូនបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស សម្រាប់បង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនកម្លាំងជាតិពិសេសប្រឆាំងភេរវកម្ម និងសាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ លើផ្ទៃប្រទេស ស្របតាមគោលការណ៍ និងបទដ្ឋានកំណត់របស់រាជរដ្ឋាភិបាល ។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្ត


0 0.5 1 2 3 4
Kilometers


Kilometers

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥. អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើអនុបយោគដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច រៀបចំបង្កើតជាភូមិតេជោមរកត ស្ថិតនៅក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពី ការបង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ "ព្រះវិហារ"

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ :

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីព្រៃសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត នូវដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋមានទំហំសរុប ៥២.៥ ហិកតា ស្ថិតក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដូចមានផែនទីជូនភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ហើយកំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម :

A (៥២២១៩៥ , ១៥៨៨២៧០) B (៥២២៣២៧ , ១៥៨៨២៧០) C (៥២២២៥៩ , ១៥៨៣៦៤៧)

D (៥២១៨៤៨ , ១៥៨៣៦៤៧) E (៥២១៣៨៣ , ១៥៨៣៦៤៨) F (៥២១៥៥០ , ១៥៨៨២៦៦)

មាត្រា ២ :

ត្រូវបានដកចេញផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការបង្កើតតំបន់ព្រៃការពារ សំរាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ "ព្រះវិហារ" ។

មាត្រា ៣ :

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ហាសិបពីរហិកតាប្រាំ (៥២,៥ ហិកតា) ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

មាត្រា ៤ :

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋទំហំ ហាសិបពីរហិកតាប្រាំ (៥២.៥ ហិកតា) ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីចុះបញ្ជីជា

ដីឯកជនរបស់រដ្ឋ សម្រាប់បែងចែកជាសម្បទានដីសង្គមកិច្ចជូនគ្រួសារយោធិន និង នគរបាលរៀបចំបង្កើតជាភូមិគោដោមរកត ស្ថិតក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល និងតម្រូវការជាក់ស្ដែង ។

មាត្រា ៥ :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១០

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១០
ស្ដីពីការកែប្រែគោលដៅប្រើប្រាស់ផ្ទៃដីព្រៃការពារ សម្រាប់សម្បទានដីសេដ្ឋកិច្ច
ជាគម្រោង ស្ថិតនៅក្នុងឃុំ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ



សញ្ញាសំគាល់

- ■ ចំណុចគោល
- ព្រំប្រទល់ព្រៃការពារ
- ព្រំប្រទល់សម្បទានដីសេដ្ឋកិច្ច
- ស្ទឹង អូរ
- ផ្លូវ
- ខ្សែរយៈកំពស់

	ទីតាំងចំណុចគោល		
1	A	522195	1584270
2	B	522327	1584270
3	C	522299	1583647
4	D	521848	1583647
5	E	521383	1583648
6	F	521650	1584286

COORDINATE SYSTEM
Projection :UTM
Zone : 48 N
Horizontal Datum : Indian 1960
Spheroid : Everest

មាត្រដ្ឋាន ១: ១០ ០០០
៩០០ ០ ៩០០ម៉ែត្រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើអនុបយោគដីព្រៃប្រមូលទុកអចិន្ត្រៃយ៍របស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច រៀបចំបង្កើតជាភូមិសែនសុខកើត ស្ថិតនៅក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូក្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ផ្ទៀងផ្ទាត់រួច

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពី ការបង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ " ព្រះវិហារ "

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ :

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីសម្រាប់ផ្តល់ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត នូវដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋមានទំហំសរុប ៨៥៧ ហិកតា ស្ថិតក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដូចមានផែនទីជូនភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ហើយកំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម :

ភូមិសែនរុងរឿង ១ មានផ្ទៃដី ៣៣១ ហិកតា

A (៥១០១៨៦, ១៥៦៣៣២៨) B (៥១០០៧២, ១៥៦៣២០៨) C (៥០៩៩២៦, ១៥៦៣០៥៤)

D (៥០៥០៩៩, ១៥៦៣៨០៨) E (៥០៩៣៤៦, ១៥៦៤០៦៦) និង F (៥០៣៧០៦, ១៥៦៦៣១៦)

G (៥០៣៦១៧, ១៥៦៥៨៥០) H (៥០៣៤៨៦, ១៥៦៥៤៧៤) I (៥០៦៨១៦, ១៥៦៤៧៤០)

J (៥០៦៨៨៦, ១៥៦៥១៥៥) K (៥០៦៩៥៩, ១៥៦៥៥៨៧)

ភូមិសែនរុងរឿង ២ មានផ្ទៃដី ១៣១ ហិកតា

A (៥១២៣៧០, ១៥៦១៣៤២) B (៥១២២០៤, ១៥៦១១៣៧) C (៥១៤១៣៧, ១៥៥៩៥៩១)

D (៥១៤៣០៣, ១៥៥៩៧៩៦) E (៥១៤៤៦៩, ១៥៦០០០១) F (៥១២៥៣៧, ១៥៦១៥៤៧)

ភូមិសែនរុងរឿង ៣ មានផ្ទៃដី ១៣៥ ហិកតា

A (៥១៦៦៦៨, ១៥៥៨៧២៩) B (៥១៦៧៧៥, ១៥៥៨៤៨៣) C (៥១៧០១៩, ១៥៥៨៥៩៧)

D (៥១៧១៩៦, ១៥៥៨៦៥២) E (៥១៧៧០៩, ១៥៥៨៥០៨) F (៥១៧៩៥៦, ១៥៥៨៤៧៣)

G (៥១៧២០៤. ១៥៥៨៥៥៩) H (៥១៩២១៨. ១៥៥៨៧០៤) I (៥១៩១៥៩. ១៥៥៨៩៦១)

J (៥១៩១១២. ១៥៥៩២២០) K (៥១៨១០០. ១៥៥៩០៧៧) L (៥១៧៨៩៨. ១៥៥៩០០៧)

M (៥១៧២២៣. ១៥៥៩១៨៩) N (៥១៧១៧៩. ១៥៥៩១៩១) O (៥១៦៨៥៤. ១៥៥៩១០០)

P (៥១៦៥៨២. ១៥៥៨៩៧២)

ភូមិសែនរុងរឿង ៤ មានផ្ទៃដី ១៣៣ ហិកតា

A (៥២២៩២៤. ១៥៥៩៤២៥) B (៥២២៩៣២. ១៥៥៩២២៧) C (៥២៥៤៧០. ១៥៥៩៥៤១)

D (៥២៥៤៤៥. ១៥៥៩៧៦៥) E (៥២៥៤០៤. ១៥៦០០៦១) F (៥២២៨៦៦. ១៥៥៩៧៤៣)

ភូមិសែនរុងរឿង ៥ មានផ្ទៃដី ១២៧ ហិកតា

A (៥១៦៩៨២. ១៥៦៨៣០៦) B (៥១៦៨៧១. ១៥៦៨៥០៤) C (៥១៦៧៥១. ១៥៦៨៧៦១)

D (៥១៨៨៤៥. ១៥៧០០៦៩) E (៥១៨៩៦៣. ១៥៦៩៨៤២) F (៥១៩០៧២. ១៥៦៩៥៩៧)

មាត្រា ២ :

ត្រូវបានដកចេញផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានក្នុងមាត្រា១ នៃអនុក្រឹត្យនេះ ចេញពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការបង្កើតតំបន់ព្រៃការពារ សំរាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ "ព្រះវិហារ" ។

មាត្រា ៣ :

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ប្រាំបីរយហាសិបប្រាំពីរហិកតា (៨៥៧ ហិកតា) ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

មាត្រា ៤ :

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋទំហំ ប្រាំបីរយហាសិបប្រាំពីរហិកតា (៨៥៧ ហិកតា) ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់បែងចែកជាសម្បទានដីសង្គមកិច្ចជូនគ្រួសារយោធិន និងនគរបាល រៀបចំបង្កើតជាភូមិសែនរុងរឿង១ ភូមិសែនរុងរឿង២ ភូមិសែនរុងរឿង៣ ភូមិសែនរុងរឿង៤ ភូមិសែនរុងរឿង៥ ស្ថិតក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល និង តម្រូវការជាក់ស្តែង ។

មាត្រា ៥ :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម

វប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



សញ្ញាសំគាល់ :
- ● ចំនុចគោល
- ▭ ព្រំប្រទល់ភូមិ
- — ផ្លូវថ្មី

COORDINATE SYSTEM
Projection: UTM
Zone: 48
Horizontal Datum: Indian 1960
Spheroid: Everest
UTM Grid: 1 Km

មាត្រដ្ឋាន ១ : ១០០ ០០០

1 0 1 2 3Km

និយាមការដែនទី១					
A	510186	1563328	F	503706	1566316
B	510072	1563208	G	503617	1565890
C	509926	1563054	I	506816	1564740
D	509099	1563808	J	506886	1565155
E	509346	1564066	K	506959	1565587

និយាមការដែនទី២		
A	512370	1561342
B	512204	1561137
C	514137	1559591
D	514303	1559796
E	514469	1560001
F	512537	1561547

និយាមការដែនទី៣					
A	516868	1558729	I	519159	1558961
B	516775	1558483	J	519112	1559220
C	517019	1558597	K	518100	1559077
D	517196	1558652	L	517898	1559007
E	517709	1558508	M	517223	1559169
F	517856	1558473	N	517179	1559191
G	518204	1558559	O	516854	1559100
H	519218	1558704	P	516582	1558972

និយាមការដែនទី៤		
A	522924	1559425
B	522932	1559227
C	525470	1559541
D	525449	1559765
E	525404	1560061
F	522866	1559743

និយាមការដែនទី៥		
A	516982	1568306
B	516871	1568504
C	516751	1568761
D	518845	1570069
E	518963	1569842
F	519072	1569597

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧. អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើអនុបយោគដីព្រៃបំរុងអចិន្ត្រៃយ៍របស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច រៀបចំបង្កើតជាភូមិសែនគេះ ស្ថិតនៅក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស្ទូ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពី ការបង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ "ព្រះវិហារ"

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ :

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត នូវដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋទំហំ ៥៨២ហិកតា ស្ថិតក្នុងភូមិសែនគេជះ ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារដូចមានផែនទីជូនភ្ជាប់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យ ហើយកំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម :

A (៥២១២៨២ , ១៥៧២៣២៤) B (៥២០២៥៦ , ១៥៧២៣២៧) C (៥២០៤៧០ , ១៥៧៥២៤៩)

D (៥២១៤៥១ , ១៥៧៥២៥៦) E (៥២២៤៦០ , ១៥៧៥២៦៣) F (៥២២២៧៥ , ១៥៧២៣២០) ។

មាត្រា ២ :

ត្រូវបានដកចេញផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានក្នុងមាត្រា ១ នៃអនុក្រឹត្យនេះចេញពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០២ ស្តីពីការបង្កើតតំបន់ព្រៃការពារ សំរាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ "ព្រះវិហារ" ។

មាត្រា ៣ :

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ប្រាំរយប៉ែតសិបពីរ ហិកតា (៥៨២ ហិកតា) ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

មាត្រា ៤ :

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋទំហំ ប្រាំរយប៉ែតសិបពីរ ហិកតា (៥៨២ ហិកតា) ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (រដ្ឋបាលព្រៃឈើ) ជាអាជ្ញាធរកាន់កាប់

ដីរដ្ឋដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់បែងចែកជាដីសម្បទានសង្គមកិច្ចជូនគ្រួសារយោធិន និង នគរបាលរៀបចំបង្កើតជាភូមិសែនជេជ: ស្ថិតក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល និង តម្រូវការជាក់ស្តែង ។

មាត្រា ៥ :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១០
ស្តីពីការកាត់ឆ្វៀលដីព្រៃពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច
ជាកម្មសិទ្ធិឯកជនរដ្ឋ: ស្ថិតនៅក្នុងឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

សញ្ញាសំគាល់

- ចំណុចកោណ
- ព្រំប្រទល់ព្រៃការពារ
- ព្រំប្រទល់សម្បទានដីសង្គមកិច្ច
- ស្ទឹង អូរ
- អូរ
- ខ្សែកម្ពស់

ចំណុចកាត់កែង

A	521292	1572324
B	520296	1572327
C	520470	1575249
D	521451	1575256
E	522460	1575263
F	522279	1572320

COORDINATE SYSTEM
Projection : UTM
Zone : 48 N
Horizontal Datum : Indian 1960
Spheroid : Everest

មាត្រដ្ឋាន ១: ៣០ ០០០
600 0 600ម៉ែត្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ២០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ ឧបដ្ឋានសាលា ផងទង់ នៅវត្តឥន្ទរង្សីមៀន ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដូចមានរាយព្រះនាម និងនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិ:

១-	ព្រះតេជគុណ	ឃួន សុភឿន	សមណៈនិស្សិតសាកលវិទ្យាល័យព្រះសីហនុរាជ	បច្ច័យ ៤២.៦៧២ ដុល្លារ
២-	ឧបាសក	អ៊ឹត ស៊ុនលី	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកា ១៥.៧២៥ ដុល្លារ
៣-	ឧបាសិកា	ចាន់ ស៊ីផន	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកា ១៣.១២៩ ដុល្លារ
៤-	លោកស្រី	យិន សាមឿន	សមាជិកក្រុមប្រឹក្សាឃុំត្រពាំងព្រះ	ថវិកា ១២.០៣១ ដុល្លារ
៥-	លោក	យិន ថេន	អាចារ្យវត្ត	ថវិកា ១២.០៣១ ដុល្លារ
៦-	លោក	អ៊ិ ម៉ុន	គណៈកម្មការវត្ត	ថវិកា ១០.៤៩៣ ដុល្លារ
៧-	លោក	ស៊ិន សុគន្ធ	គណៈកម្មការវត្ត	ថវិកា ១០.៤៩៣ ដុល្លារ
៨-	លោក	គឹម ផល	គណៈកម្មការវត្ត	ថវិកា ១០.០៦២ ដុល្លារ
៩-	ឧបាសក	ឈា ឆេងឡេង	សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា	ថវិកា ១០.០៥១ ដុល្លារ

១០-	លោក	មាស សុខ	សហព្រះសង្ឃនៅរាជធានីភ្នំពេញ	ថវិកា ១០.០២៥ ដុល្លារ
១១-	លោក	យុន សារុន	គណៈកម្មការវត្ត	ថវិកា ១០.០១៨ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិៈ

១-	លោក	ស៊ូ ស៊ាន	អាចារ្យវត្ត	ថវិកា ៥.៧៩១ ដុល្លារ
២-	លោក	ចោ ច័ន	អាចារ្យវត្ត	ថវិកា ៥.៧៥២ ដុល្លារ
៣-	ឧបាសិកា	ស៊ូ ចេង	គណៈកម្មការវត្ត	ថវិកា ៥.៤៨៧ ដុល្លារ
៤-	ឧបាសិកា	ស៊ី ឈុនឈូង	គណៈកម្មការវត្ត	ថវិកា ៥.៤២៩ ដុល្លារ
៥-	លោក	យ៉ាង់ ឈង់	អាចារ្យវត្ត	ថវិកា ៥.២៣៦ ដុល្លារ
៦-	ឧបាសិកា	ផាង់ ឈាងស៊ីម	គណៈកម្មការវត្ត	ថវិកា ៥.១៧៣ ដុល្លារ
៧-	ឧបាសក	ម៉ុក សុខ	សហព្រះសង្ឃនៅខេត្តកំពង់ចាម	ថវិកា ៥.០៣៦ ដុល្លារ
៨-	ឧបាសក	ចេង ម៉េង	សហព្រះសង្ឃនៅខេត្តកំពង់ចាម	ថវិកា ៥.០៣៣ ដុល្លារ
៩-	ឧបាសក	ឈួន តឹក	សហព្រះសង្ឃនៅខេត្តកំពង់ចាម	ថវិកា ៥.០២៤ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ[illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរវជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ប្រគេន និងជូនសប្បុរសជន ចំនួន ០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងឧបដ្ឋានសាលាមួយខ្នង ស្ថិតនៅវត្តអង្គតាឯក ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាម និងនាមខាងក្រោម ៖

១-ព្រះតេជគុណ	ទួន ផល	ព្រះចៅអធិការវត្តអង្គតាឯក
២-លោក	ទួន ខេង	និងអ្នកស្រី
៣-លោក	ទួន សុខឃុត	និងអ្នកស្រី
៤-លោក	ទួន សាំង	និងអ្នកស្រី
៥-លោក	ណារី ម៉ែរហេង	និងអ្នកស្រី

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរវជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបាន[illegible] ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១០ ៕

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន នៃសមាគម Infants Delmon ចំនួន០៧រូប ដែលបានផ្តល់ថវិកា សរុបចំនួន ២៤០.១២៥ ដុល្លារអាមេរិក ក្នុងការជួយសាងសង់មជ្ឈមណ្ឌល ០១កន្លែង សម្រាប់ចិញ្ចឹមកុមារកំព្រា កុមារក្រីក្រ ដោយអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងបញ្ជូនទៅរៀនសូត្រក្នុងសាលារដ្ឋ និងជួយសាងសង់អគារសិក្សា ចំនួន០២ខ្នង មាន៣១បន្ទប់ ធ្វើអំពីថ្ម ប្រក់ក្បឿង នៅឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

1-SENYOR	ALBERT PINTAT.	CAP DE GOVERN D'ANDORRA
2-SENYORA	MERITXELL MATEU,	MINISTRA D'AFERS EXTRIORS
3-SENYOR	STEPHAN YATES,	BENEFACTOR I.D.M ANDORRA
4-SENYORA	ELISABET PLANAS,	PRESIDENTA I.D.M ANDORRA
5-Mr. OEUR	CHAMROEUN,	MEMBER ASSOCIATION I.D.M.C
6-SENYORETA	ANNA ARAUJO,	CONSELLERA DELEGADA F.I.D.M.C

7-Mr. DENG VITH, CHEF BUREAU DE L'EDUCATION JEUNESSE ET SPORTS

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងអគារសិក្សា ០១ខ្នង ០៣ជាន់ មាន១៥បន្ទប់ ជួសជុលអគារសិក្សា ០១ខ្នង ដើម្បីរៀបចំបណ្ណាល័យ កសាងទីលានបាល់ទះ បាល់ទាត់ ជូនសាលាបឋមសិក្សាបឹងសាឡាង និង អគារសិក្សា០១ខ្នង ០៣ជាន់ មាន១៥បន្ទប់ ធ្វើពីឥដ្ឋប្រក់ក្បឿង ជូនវិទ្យាល័យជាស៊ីម-សាមគ្គី សរុបថវិកាចំនួន ៧០០.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :-

១-លោក **Christian Des Pallieres** ប្រតិភូនៃអង្គការដើម្បីភាពញញឹមនៃកុមារប្រចាំប្រទេសកម្ពុជា

២-លោកស្រី **Marie Christian Des Pallieres** ប្រតិភូនៃអង្គការដើម្បីភាពញញឹមនៃកុមារប្រចាំប្រទេសកម្ពុជា

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់គ្រឿងឥស្សរិយយសសុវត្ថារា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសសុវត្ថារា** តាមលំដាប់ថ្នាក់ ផ្តល់ជូនមន្ត្រីនគរបាលជាតិ នៃនាយកដ្ឋានអន្តោប្រវេសន៍ ប្រចាំការនៅប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ ដែលបានអនុវត្តន៍ភារកិច្ចបានល្អប្រសើរ និងលះបង់ថវិកាផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាជាច្រើននៅក្នុងខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

ក. មេដាយសុវត្ថារាថ្នាក់និមន្ទ ចំនួន ២៣ គ្រឿង ផ្តល់ជូន :

១-លោកវរសេនីយ៍ទោ សំរិទ្ធ ឡេង នាយប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១២១៤៣

២-លោកវរសេនីយ៍ទោ ម៉ក់ ពិន្ទុ នាយការិយាល័យ អត្តលេខ ១៥៦៤៣

៣-លោកវរសេនីយ៍ត្រី សោម ផានិត្យ នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៤៥៥៦

៤-លោកវរសេនីយ៍ត្រី ទិ ចិន្តា នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១៦២៦៩

៥-លោកវរសេនីយ៍ត្រី ម៉ឺន ទាសនា នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១២៤២៤

៦-លោកវរសេនីយ៍ត្រី អ៊ុំ ករុណា នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៨៥៨៩

៧-លោកវរសេនីយ៍ត្រី ម៉ឺន ហុក នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៩៥៩៤

៨-លោកអនុសេនីយ៍ឯក ម៉ឺន កល្យាណ នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥៤១៥០

៩-លោកវរសេនីយ៍ត្រី នួន ធនលាភ នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១២១៩២

១០-លោកវរសេនីយ៍ត្រី ស៊ឿន ចំនួនសារិទ្ធ នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១២២១៩

១១-លោកវរសេនីយ៍ត្រី ហ៊ុន និមល នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៥៧៣៥

១២-លោកវរសេនីយ៍ត្រី ស្វាយ រិន នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៩៧៧៤

១៣-លោកវរសេនីយ៍ត្រី ចាន់ សារិន នាយរងការិយាល័យ អត្តលេខ ០៣៣១០

១៤-លោកអនុសេនីយ៍ឯក សាន់ ទីរ៉ាត់ នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៨១២៣

១៥-លោកអនុសេនីយ៍ទោ គិម យ៉ាឌី នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥៩១០៥

១៦-លោកអនុសេនីយ៍ឯក អ៊ូ ច័ន្ទសុខា នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៨០៧៣

១៧-លោកអនុសេនីយ៍ឯក ឯក សារ៉ុន នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១៦២៨៥

១៨-លោកអនុសេនីយ៍ទោ ខន ពុធសុវណ្ណ នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០១២៧៣២

១៩-លោកអនុសេនីយ៍ទោ យ៉េន សុផល នាយប៉ុស្តិ៍ការពារព្រំដែន អត្តលេខ ១៦៦៩៩

២០-លោកអនុសេនីយ៍ទោ ហេង ប៊ុនស៊្រុន នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៨៤៤៤

២១-លោកអនុសេនីយ៍ត្រី ស ចំសោល នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៨៣៦២

២២- លោកអនុសេនីយ៍ត្រី អ៊ុត សុភាព នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥០៥០៥

២៣-លោកព្រិន្ទបាលឯក ម៉ា សុខា នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៧៥៩៧

ខ. មេដាយសុវត្ថារាជ្ជាអាសនាថ្នាក់សេនាចំនួន ០៧ គ្រឿង ផ្តល់ជូន ៖

១-លោកវរសេនីយ៍ទោ ខាត់ សារ៉ាត់ នាយប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៩៩៦៥

២-លោកវរសេនីយ៍ទោ ជីម លី អនុកណ្តាលបទល្មើស អត្តលេខ ០១៩៩៥

៣-លោកវរសេនីយ៍ត្រី កែម សារ៉ូឌី នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៧០៣៩

៤-លោកវរសេនីយ៍ត្រី មាន គុន្ធរា នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៨៣៧៣

៥-លោកវរសេនីយ៍ត្រី ខាំ ដែងច័ន្ទចត្តី នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៣០៣៣

៦-លោកអនុសេនីយ៍ឯក សឿង នី នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១២២២៥

៧-លោកអនុសេនីយ៍ទោ ទីន ពិសិទ្ធ នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥៦៦១៣

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៥៤..អនក្រ..បក

អនុក្រឹត្យ

ស្តីពីការផ្តល់គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូនមន្ត្រីនគរបាលជាតិ នៃនាយកដ្ឋានអន្តោប្រវេសន៍ ប្រចាំការនៅប៉ុស្តិ៍ច្រកទ្វារអន្តរជាតិចំនួន ៣១រូប ដែលបានអនុវត្តនីភារកិច្ចបានល្អប្រសើរ និង លះបង់ថវិកាផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាជាច្រើននៅក្នុងខេត្តព្រៃវែង ដែលមានរាយនាម ដូចខាងក្រោម :

ក- មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ២៩ គ្រឿង ផ្តល់ជូន :

១-លោកវរសេនីយ៍ទោ **សោម សុគន្ធ** នាយប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៥៥០៦
២-លោកវរសេនីយ៍ទោ **គុច សុចន្ទ្រា** នាយប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៦៧៨៨
៣-លោកវរសេនីយ៍ទោ **សែម ណារិន** បញ្ជាការរង អត្តលេខ ០៩៣៩៦
៤- លោកវរសេនីយ៍ទោ **ខេត ចន្ទ្រា** នាយរងការិយាល័យ អត្តលេខ ០៤៧៨៩
៥-លោកវរសេនីយ៍ត្រី **អ៊ុំ ចំនួនសារិទ្ធ** មេបញ្ជាការរងវរៈអត្តលេខ ២២៥២៧
៦-លោកវរសេនីយ៍ត្រី **គុច សារ៉េត** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៦៧៨៦
៧-លោកវរសេនីយ៍ត្រី **ឃឹម ចាន់ឌុល** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ អត្តលេខ ០១២៤៣៣
៨-លោកវរសេនីយ៍ត្រី **អ៊ិត ឡុង** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៩៣៥២

៩-លោកវរសេនីយ៍ត្រី **ហ៊ា សុខុន** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១៦២៧៧
១០-លោកវរសេនីយ៍ត្រី **ឆេស គីមស្រ៊ាង** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១២៤៥៩
១១-លោកវរសេនីយ៍ត្រី **សៀម សុធារ** នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៦១៦៦៦
១២-លោកវរសេនីយ៍ត្រី **ជួន សារី** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៥៩១២
១៣-លោកវរសេនីយ៍ត្រី **ញឹម សុខលី** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៧២០៩
១៤-លោកវរសេនីយ៍ត្រី **អ៊ុន សម្ផស្ស** បញ្ជាការរងវេរ: អត្តលេខ ១៥៨៥៣
១៥-លោកវរសេនីយ៍ត្រី **ហំ សិទ្ធិ** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៤១៥២
១៦-លោកវរសេនីយ៍ត្រី **អ៊ុន ស៊ើរិទ្ធិ** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៧០៩៣
១៧-លោកអនុសេនីយ៍ឯក **នាយ ពុទ្ធវណ្ណា** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៤១៩៨
១៨-លោកអនុសេនីយ៍ឯក **ព្រហ្ម គាត** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៤៣៨២
១៩-លោកអនុសេនីយ៍ឯក **ហ៊ិន គីមហុង** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១៦២៨៦
២០-លោកអនុសេនីយ៍ឯក **ម្សី សារ៉ុន** នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥២២៣០
២១-លោកអនុសេនីយ៍ឯក **សែម សុផល** នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៥៧៥៥
២២-លោកអនុសេនីយ៍ឯក **ជាម ដារ៉ា** នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៤១៣៣
២៣-លោកអនុសេនីយ៍ឯក **នៅ សុធារ៉ា** នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០១៦២៥៣
២៤-លោកអនុសេនីយ៍ទោ **ខួន យុលាង** នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១៧១៧៤
២៥- លោកអនុសេនីយ៍ទោ **ធុំ ផាណិត** នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៤៤៩០
២៦- លោកអនុសេនីយ៍ទោ **នឹម សុខា** នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៥២៣៥
២៧- លោកអនុសេនីយ៍ទោ **ម៉ែន សុខា** នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ២០៨៥៣
២៨- លោកអនុសេនីយ៍ទោ **ជា មករា** នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥៧៥០៨
២៩- លោកអនុសេនីយ៍ទោ **ជា ចំរើន** នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៤១៥៧

ខ_ មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនាចំនួន ០២ គ្រឿង ផ្តល់ជូន :

១- លោកអនុសេនីយ៍ត្រី **ចាម ណារិន** នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៦២០៩៦
២- លោកអនុសេនីយ៍ត្រី **ម្ល៉ា លីម៉េង** មន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៦៣០៤៧

មាត្រា ២ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១០

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៥៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការផ្តល់គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សរិទ្ធិ** ប្រគេន និងផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជនចំនួន ០៤រូប ដែលបានលះបង់កំលាំងកាយចិត្ត និងថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និងសង្គមកិច្ច ស្ថិតនៅក្នុងស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១-ព្រះតេជគុណ **មាស ឡិ** ព្រះគ្រូអនុគណសង្ឃ ស្រុកកញ្ជ្រៀច
២-ព្រះតេជគុណ **ឃ្លីយ សេខហ៊ី** ព្រះចៅអធិការវត្តធម្មកេរ្តិ៍ ស្រុកកញ្ជ្រៀច
៣-ព្រះតេជគុណ **ឆៀង គា** គង់នៅវត្តធម្មកេរ្តិ៍ ស្រុកកញ្ជ្រៀច
៤- លោកអនុសេនីយ៍ឯក **សួន សាចំន្ត** នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧...អនក្រ.តត

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្តល់ជូនមន្ត្រីរាជការចំនួន ០៣ រូប ដែលបានលះបង់កំលាំងកាយ ចិត្ត និងថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងសង្គមកិច្ច ស្ថិតនៅក្នុងស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

១-លោក **សិន ស៊ុនសុភក្តិ** អនុប្រធានការិយាល័យ ក្រសួងមហាផ្ទៃ

២-លោក **កែវ គុជសី** មន្ត្រីក្រសួងមហាផ្ទៃ

៣-លោក **ថ្លាត់ ធន** សប្បុរសជននៅខេត្តព្រៃវែង

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **និមនិត្ត** ជូន កងឯកភាព ចំនួន ០៣ នៃ សាធារណៈរដ្ឋសង្គមនិយមវៀតណាម ដែលមានស្នាដៃល្អក្នុងការជួយកសាង សាលប្រជុំ . ផ្ទះសំណាក់ការិយាល័យ និងកិច្ចសហប្រតិបត្តិការលើវិស័យយោធាជាមួយតំបន់ប្រតិបត្តិការសឹករងកោះកុង ដូចមានរាយខាងក្រោម :-

១ យោធភូមិភាគទី ៩ នៃ កងទ័ពប្រជាជនវៀតណាម

២ គណៈកម្មាធិការប្រជាជន ខេត្ត បាក់លៀវ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម

៣ គណៈកម្មាធិការប្រជាជន ខេត្ត គៀងយ៉ាង នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី.
- បានឃើញអនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្ដីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា ១: ត្រូវបានតែងតាំងលោក **ម៉ូ រតនា** ជាជំនួយការឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ មានឋានៈស្មើ **អគ្គនាយករង** ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះ [illegible] តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ [illegible] ឆ្នាំ ២០១០

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..៥៩....អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនសប្បុរសជនចំនួន ០៤ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងសង្គមកិច្ច ស្ថិតនៅក្នុងស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

១-ឯកឧត្តម	**ជា ណា**	សមាជិកក្រុមប្រឹក្សាខេត្តកំពង់ធំ	ថវិកាចំនួន ៤៥.០០០ ដុល្លារ
២-លោក	**ខោ សាន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៤២.៨០០ ដុល្លារ
៣-លោក	**ជា តាន**	សប្បុរសជននៅខេត្តព្រៃវែង	ថវិកាចំនួន ៤១.៥០០ ដុល្លារ
៤-លោកជំទាវ	**ជួន សារឿន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៤១.៣០០ ដុល្លារ

មាត្រា ២.—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៦៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងលោក **វ៉ើល ម៉ើន** ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១២៧ អនក្រ បក ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការបង្កើតសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការស៊ីវិល នៃក្រសួងសុខាភិបាលមួយចំនួន ដូចខាងក្រោម :

១-លោកស្រីឱសថការី **នេត ចន្ទ្រី** ជាព្រឹទ្ធបុរសមហាវិទ្យាល័យឱសថសាស្ត្រ ជំនួសលោកស្រី **ទា សុខគេង** ដែលបានចូលនិវត្តន៍

២-លោកទន្តបណ្ឌិត **អ៊ឹម ពុទ្ធរាទី** ជាព្រឹទ្ធបុរសមហាវិទ្យាល័យទន្តវេទនសាស្ត្រ ជំនួសលោក **ស៊ួន ផានី** ដែលបានចូលនិវត្តន៍

៣-លោកវេជ្ជបណ្ឌិត **អៀម សុផល** ជានាយកសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ ជំនួសលោក **ហ៊ុយ សុវ៉ាត** ដែលបានចូលនិវត្តន៍

៤-លោកឱសថការី **សេខ ប៊ុនគៀត** ជាប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ជំនួសលោកស្រី **មា ងឹមហាយ** ដែលបានចូលនិវត្តន៍។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

មាត្រា ១ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់**ក្រសួងផែនការ** ឱ្យចូលនិវត្តន៍ ដោយនៅរក្សាក្របខ័ណ្ឌនយោបាយដដែលរហូតមានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល មាននាមដូចខាងក្រោម :

១	**សុ ឈាត**	ប	រដ្ឋលេខាធិការ	**ក.២.១**	ចូលនិវត្តន៍ពីថ្ងៃទី ០១-០៦-២០១០

មាត្រា ២ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ឱ្យចូល និវត្តន៍ ដូចមានរាយនាមខាងក្រោម :

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា					
១	**ម៉ៅ សុខន្តី**	ប	អគ្គនាយករង	**ក.២.៥**	ចូលនិវត្តន៍ពីថ្ងៃទី ០១-០១-២០១០
២	**ជុំ សៀកខូន**	ប	ប្រធាននាយកដ្ឋាន	**ក.២.៥**	ចូលនិវត្តន៍ពីថ្ងៃទី ០១-០៧-២០០៩
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ					
១	**ឡាច សុជាតិ**	ប	នាយកវិទ្យាស្ថាន	**ក.២.១០**	ចូលនិវត្តន៍ពីថ្ងៃទី ០១-១២-២០០៩
ក្រសួងពាណិជ្ជកម្ម					
១	**ម៉ី សាម៉ែន**	ប	អគ្គនាយករង	**ក.២.៣**	ចូលនិវត្តន៍ពីថ្ងៃទី ០១-០៣-២០១០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ស ម្រេ ច

មាត្រា ១ : ត្រូវបានដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ... ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឱ្យចូលនិវត្តន៍ ដោយនៅរក្សាក្របខ័ណ្ឌនយោបាយដែលរហូតមានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល មាននាមដូចខាងក្រោម :

១	ឯក ចន្ធូមី	ប	រដ្ឋលេខាធិការ	វរមន្ត្រី ថ្នាក់លេខ ៩	ថ្ងៃខែចូលនិវត្តន៍ ០១-០៣-២០១០

មាត្រា ២ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងយុត្តិធម៌ ឱ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម :

១	ឡើង ឆាយ	ប	ប្រធាននាយកដ្ឋាន	វរមន្ត្រី ថ្នាក់លេខ ២	ថ្ងៃខែចូលនិវត្តន៍ ០១-១២-២០០៩

មាត្រា ៣ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិវរមន្ត្រីការបរទេស នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឱ្យចូលនិវត្តន៍ ដូចមាននាមខាងក្រោម :

១	ស៊ី ៩ន	ប	អគ្គាធិការរង	វរមន្ត្រីការបរទេស ថ្នាក់លេខ ៣	ថ្ងៃខែចូលនិវត្តន៍ ០១-១១-២០១០
២	ហៃ សុខារិទ្ធ	ស	ប្រធាននាយកដ្ឋាន	វរមន្ត្រីការបរទេស ថ្នាក់លេខ ៤	ថ្ងៃខែចូលនិវត្តន៍ ០១-១១-២០១០
៣	កៅ ស៊ីនួ	ប	អគ្គទីប្រឹក្សា	វរមន្ត្រីការបរទេស ថ្នាក់លេខ ៥	ថ្ងៃខែចូលនិវត្តន៍ ០១-១០-២០១០

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង

ក្នុងមាត្រា ១ មាត្រា ២ និងមាត្រា ៣ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៤ អនក្រ.តត

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.–

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជនចំនួន ០៨ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ និងសង្គមកិច្ច ស្ថិតនៅក្នុងឃុំរលួច និងឃុំប្រធាតុ ស្រុកស៊ីធរកណ្តាល និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១-ព្រះតេជគុណ	**ខាត់**	**ញ៉ឹម**	ព្រះចៅអធិការវត្តព្រៃពោធិ៍	បច្ច័យចំនួន ១២.៣០០ ដុល្លារ
២-លោកជំទាវ	**ម៉ែ**	**គីមឃីត**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១២.៨០០ ដុល្លារ
៣-លោក	**ស៊ឹម**	**ចាក់**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១២.៣០០ ដុល្លារ
៤-លោកស្រី	**គង**	**សារ៉េត**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១១.០៥០ ដុល្លារ
៥-លោកស្រី	**ផែន**	**សុផល**	សប្បុរសជននៅខេត្តព្រៃវែង	ថវិកាចំនួន ១០.៩២០ ដុល្លារ
៦-លោកស្រី	**ម៉ែត**	**សុភា**	សប្បុរសជននៅខេត្តព្រៃវែង	ថវិកាចំនួន ១០.៧៧០ ដុល្លារ
៧-លោកស្រី	**ខែត**	** និន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១០.៣២០ ដុល្លារ
៨-លោក	**ហ៊ុន**	**ចាសនា**	អនុប្រធានសាខាគយខេត្តកោះកុង	ថវិកាចំនួន ១០.១៥០ ដុល្លារ

មាត្រា ២.–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៦៥..អនក្រ..បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
